១៣

# ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយអ្នកដទៃ

ពង្រឹងមិត្តភាពជាមួយមនុស្សផ្សេងទៀតក្នុងនាមជាគ្រីស្ទបរិសទ៍

**សៀវភៅសំរាប់សិស្ស**

សិក្សាជាក្រុម

**សំរាប់**គ្រិស្តបរិស័ទថ្មី

ចំរើនភាពទៀន
នៃកម្ពុជា

# មាតិការ


**ជំពូក ១. មិត្តភ័ក្តិ ........................................................ ៣**

ក. តើអ្នកអាចក្លាយទៅជាមិត្តភ័ក្តិល្អដោយរបៀបណា? ........................ ៣

ខ. ប្រភេទផ្សេងៗគ្នានៃមិត្តភ័ក្តិ ........................................ ៤

គ. ចុះចំណែកឯមិត្តភ័ក្តិចាស់ពីចញ្ចៀមផ្តល់នោះយ៉ាងម៉េចដែរ? .................... ៧

ឃ. ការឆ្លើយតបចំពោះសត្រូវរបស់អ្នក ( អតីតមិត្តភ័ក្តិ ) ....................... ៧

**ជំពូក ២. ផ្លូវភេទ និង ជីវិតគ្រីស្ទបរិស័ទ ........................................ ៨**

ក. ការណាត់ជួបគូរសង្សារ ........................................................ ៨

១. តើគោលបំណងនៃការណាត់ជួបគូរសង្សារគឺជាអ្វី? ................................ ៨

២. តើនៅពេលណាមនុស្សវ័យណាអាចចាប់ផ្តើមការណាត់ជួបគូរសង្សារបាន? .............. ៩

៣. តើផលប្រយោជន៏អ្វីខ្លះនៃការណាត់ជួបគូរសង្សារ? .............................. ៩

៤. តើគ្រោះថ្នាក់អ្វីខ្លះនៃការណាត់ជួបគូរសង្សារ? ................................ ៩

ខ. អាពាហ៏ពិពាហ៏ ............................................................. ៩

១. តើអ្នកអាចរៀបចំខ្លួនអ្នកសំរាប់អាពាហ៏ពិពាហ៏ដ៏ជោគជ័យមួយបានដោយរបៀបណា? ........ ៩

២. គំរូរបស់ព្រះជាម្ចាស់សំរាប់អាពាហ៏ពិពាហ៏ដ៏ជោគជ័យមួយ ......................... ១១

# ជំពូក ទី១

# មិត្តភ័ក្តិ

## ក. តើអ្នកអាចក្លាយទៅជាមិត្តភ័ក្តិល្អដោយរបៀបណា?

សំនួរដំបូងពីរនៅក្នុងគំរោង ទី ១ ក្នុងសៀវភៅណែនាំការសិក្សាសំរាប់មុខវិជ្ជានេះអាចផ្តល់អោយអ្នកនូវគំនិតខ្លះ សំរាប់ផ្នែកនៃមេរៀននេះ ។ មនុស្សដែលជាមិត្តភ័ក្តិដ៏ល្អបំផុតរបស់អ្នកប្រហែលជាមានលក្ខណៈសម្បត្តិល្អខ្លះៗនៅក្នុងជីវិតរបស់ពួកគេ ដែលធ្វើអោយមានការងាយស្រួលសំរាប់អ្នកក្នុងការចូលចិត្តពួកគេ ។

លក្ខណៈសម្បត្តិល្អៗដូចគ្នាទាំងនោះអាចជួយអោយអ្នកក្លាយជាមិត្តដ៏ល្អបានផងដែរ ។ នៅពេលដែលអ្នកខិតខំធ្វើអោយវាប្រសើរឡើងនូវលក្ខណៈសម្បត្តិទាំងនេះ អ្នកដទៃនឹងចង់ក្លាយជាមិត្តភ័ក្តិរបស់អ្នក ។

នេះគឺជាគំនិតខ្លះៗដែលអ្នកដទៃបានពន្យល់បង្ហាញពីរបៀបដែលពួកគេអាចក្លាយទៅជាមិត្តល្អ ។

១. ខ្វល់ខ្វាយអំពីអ្នកដ៏ទៃ

២. បង្ហាញសេចក្តីស្រលាញ់ដល់ពួកគេ

៣. ព្យាយាមនិយាយរឿងកំប្លែងខ្លះៗដែលសមរម្យ

៤. ធ្វើកិច្ចការដើម្បីជួយអ្នកដទៃ

៥. បង្ហាញចិត្តសប្បុរសដល់អ្នកដទៃ

៦. អាចរកជួបបាននៅពេលពួកគេត្រូវការជំនួយ

៧. ស្តាប់ពួកគេ

៨. ព្យាយាមយល់ដឹងពីពួកគេ

៩. លើកទឹកចិត្តអ្នកដទៃ

១០. កុំមើលងាយអ្នកដទៃ

១១. រៀនពីរបៀបទុកចិត្តមនុស្សដទៃ

ព្រះគម្ពីរបាននិយាយយ៉ាងច្រើនអំពីការបង្កើតមិត្តភាពល្អ ។ កណ្ឌគម្ពីរសុភាសិតពោរពេញទៅដោយ គំនិតយោបល់ពីរបៀបក្លាយទៅជាមិត្តភ័ក្តិល្អ និង អ្វីដែលបំផ្លាញមិត្តភាព ។ ទាំងនេះគឺជាអត្ថបទគម្ពីរខ្លះៗ:

សុភាសិត ១៧:៩

សុភាសិត ១៧:១៧

សុភាសិត ១២:២៥, ២៦

យ៉ូហាន ១៥:១២-១៥

## ២. ប្រភេទផ្សេងៗគ្នានៃមិត្តភ័ក្តិ

យើងចូលចិត្តមនុស្សខ្លះច្រើនជាងមនុស្សដទៃទៀត នោះវាជារឿងធម្មតាទេ ។ អ្នកអាចមានមិត្តភ័ក្តិជាច្រើន និងអ្នកអាចមានប្រភេទផ្សេងៗគ្នានៃមិត្តភាព ។ នេះគឺជាគំនិតខ្លះៗនៅលើប្រភេទផ្សេងៗគ្នា ៤ យ៉ាងនៃមិត្តភាព ។ មិត្តភ័ក្តិរបស់អ្នកភាគច្រើនប្រហែលជាអាចស៊ីគ្នាទៅនឹងក្រុមមួយនៃក្រុមទាំងនេះ ។

សូមអោយយើងមើលអោយកាន់តែជិតនូវប្រភេទ ៤ យ៉ាងនៃមិត្តភាពទាំងនេះ ។ ការពិពណ៌នាដោយសង្ខេបនឹងត្រូវបានផ្តល់ជូននៅលើចំនុចទីមួយៗ ។ បន្ទាប់មកចូលមកដល់ការពន្យល់អ្វីជាសេរីភាពរបស់អ្នកជាមួយនឹងកំរិតនៃ មិត្តភាព ។ ចុងក្រោយចូលមកដល់ការពិពណ៌នានៃការទទួលខុសត្រូវរបស់អ្នកចំពោះមិត្តភ័ក្តិប្រភេទនេះ ។

មែនហើយ--ប្រសិនបើអ្នកនឹងក្លាយទៅជាមិត្តដ៏ល្អរបស់អ្នកដទៃ អ្នកត្រូវតែសុខចិត្តទទួលយកការទទួលខុសត្រូវ ។ ពេលណាមានសេរីភាព ពេលនោះមានការទទួលខុសត្រូវជាក់លាក់ទៅជាមួយនឹងសេរីភាពនោះផងដែរ ។

គំនិតភាគច្រើនសំរាប់វគ្គនេះគឺផ្អែកលើការកត់ចំណាំចេញពីវិទ្យាស្ថាននៃសិក្ខាសាលាជាមូលដ្ឋានដោះជំលោះរបស់យុវជន ។ យើងទទួលស្គាល់យ៉ាងសប្បាយរីករាយ ដែលអង្គសិក្ខាសាលានេះមានឥទ្ធិពលដល់អ្នកដែលបានចងក្រងសៀវភៅ និង មេរៀននេះឡើង ។

### ១. មនុស្សដែលស្គាល់

ក. ការពិពណ៌នា

អ្នកឃើញគាត់ម្តងម្កាល ហើយអ្នកស្គាល់ឈ្មោះរបស់គាត់ ។

ខ. សេរីភាពរបស់អ្នក

អ្នកមានសិទ្ធិសួរសំនួរទូទៅខ្លះ ។ សំនួរដែលសុំពតិមានជាសាធារណៈ : "តើអ្នកមានឈ្មោះអ្វី? តើអ្នករស់នៅឯណា? តើអ្នកធ្វើការនៅឯណា? តើអ្នកទៅរៀននៅឯណា?

គ. ការទទួលខុសត្រូវរបស់អ្នក

(១) មើលលើចំនុចទីមួយៗ " កិច្ចជួបគ្នាជាមួយព្រះជាម្ចាស់ " ។ ការជួបមនុស្សអាចបទពិសោធន៏មួយដ៏ល្អ ប្រសិនបើអ្នកយល់ដឹងថា ព្រះជាម្ចាស់បាននាំមនុស្សនេះមកក្នុងជីវិតរបស់អ្នក ពីព្រោះព្រះអង្គចង់ប្រើអ្នកអោយក្លាយជាការប្រទានពរនៅក្នុងជីវិតរបស់មនុស្សនេះ ។ ប៉ុន្តែ នោះមិនមែនមានន័យថា រាល់មិត្តភាពទាំងអស់គឺជាមិត្តភាពរលូនល្អនោះទេ ។ មនុស្សខ្លះប្រហែលជាព្យាយាមអោយអ្នកឃ្លាតឆ្ងាយចេញពីព្រះជាម្ចាស់ ។

វិធីមួយដើម្បីការពារខ្លួនអ្នកនៅក្នុងមិត្តភាពប្រភេទនេះគឺអោយព្រះជាម្ចាស់ជាប់ទាក់ទងនៅក្នុងទំនាក់ទំនងនេះ ។ មុននឹងអ្នកធ្វើអោយមិត្តភាពនេះកាន់តែជ្រៅថែមទៀត អ្នកចាំបាច់ត្រូវធ្វើអោយប្រាកដថា បំណងរបស់អ្នកគឺស្មោះស និងអ្នកមានសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ក្នុងការធ្វើកិច្ចការនេះ ។

(២) អ្នកត្រូវតែបង្កើតសំនួរទូទៅដើម្បីប្រើនៅក្នុងការសន្ទនាជាមួយនឹងពួកគេ ។ សំនួរទាំងនេះមិនមែនជាសំនួរបំភិតបំភ័យនោះទេ ។ យើងគួរតែសួរសំនួរអោយកាន់តែមានភាពស្និតស្នាលស្តីអំពីជីវិតរបស់មនុស្សនោះ ។

មនុស្សដែលស្គាល់នឹងប្រហែលជាក្រុមមួយដែលមានមនុស្សយ៉ាងច្រើនជាមិត្តភ័ក្តិរបស់អ្នក ។ អ្នកអាចមានមនុស្ស ១០០ នាក់ ឬក៏ ច្រើនជាង ដែលអ្នកស្គាល់ ។

វិធីមួយដែលត្រឹមត្រូវក្នុងការឆ្លើយតបនៅពេលជួបមនុស្សថ្មីគឺ ...

-- ចាប់អារម្មណ៏ចំពោះពួកគេ

-- ទទួលយកពួកគេថាជានរណា

-- បង្ហាញតាមរយៈសកម្មភាព និង ពាក្យសំដីរបស់អ្នកថា អ្នកជឿមនុស្សនេះសំខាន់ អ្នកផ្តល់តំលៃមិត្តភាពនេះ ។

-- ជាអ្នកស្តាប់ដ៏ល្អ ។ព្យាយាមមើលឃើញអ្វីដែលព្រះជាម្ចាស់កំពុងតែធ្វើនៅក្នុងជីវិតរបស់គាត់ ។

## ២. មិត្តភាពធម្មតា

មិត្តភាពធម្មតាគឺមានភាពស៊ីជំរៅជាងតិចតួចចំពោះមនុស្សដែលស្គាល់សើរ១

### ក. ការពិពណ៌នា

ប្រភេទនៃមិត្តភាពនេះមានផ្តើតទៅលើចំណាប់អារម្មណ៍ និង សកម្មភាពដូចគ្នាដែលអ្នកទាំងពីរមាន ។ ឧទាហរណ៏ អ្នកទាំងពីរចូលចិត្តលេងបាល់បោះ, ឬក៏ រ៉ាកែត ឬក៏ ជិះសេះ ។ ឬក៏ ប្រហែលជាអ្នកទាំងពីរចូលចិត្តការងារដូចគ្នា រឺចំណង់ចំណូលចិត្តដូចគ្នា ។ អ្នកប្រហែលអាចមានចំណាប់អារម្មណ៏ប្រហាក់ប្រហែលគ្នា ដែលធ្វើអោយមានភាពងាយស្រួលសំរាប់អ្នកក្នុងការបង្កើតមិត្តភ័ក្តិដ៏សាមញ្ញមួយបាន ។

### ខ. សេរីភាពរបស់អ្នក

អ្នកមានសេរីភាពក្នុងការសួរសំនួរចំ១ ។ ឧទាហរណ៏ សំនួរដែលទាក់ទងនិងគោលគំនិតរបស់ពួកគេទៅលើប្រធានបទណាមួយ ឬក៏ គោលដៅនៅក្នុងជីវិតរបស់ពួកគេ ។

### គ. ការទទួលខុសត្រូវរបស់អ្នកចំពោះមិត្តភាពនេះ

(១) អ្នកត្រូវស្វែងរកចំនុចល្អនៅក្នុងពួកគេ ។ តើលក្ខណៈសម្បត្តិវិជ្ជមានណាខ្លះ ដែលមាននៅក្នុងជីវិតរបស់ពួកគេ? សូមមើល **ភីលីព ៤:៨-៩**

(២) អ្នកត្រូវរៀនសួរសំនួរចំ១ ហើយច្បាស់១ ដែលល្អទៅដល់ពួកគេ ។ សូមស្តាប់ឱ្យបានប្រុងប្រយត្ន័ ហើយសួរសំនួរដែលទាក់ទងនិងចំណាប់អារម្មណ៏របស់មិត្តភ័ក្តិអ្នក ។

អ្នកអាចមានមិត្តភ័ក្តិធម្មតា១ជាច្រើនបាន ។ នៅក្នុងករណីជាច្រើន ចំណាប់អារម្មណ៏ដូចគ្នា ដែលអ្នកមានស្រដៀងនិងមនុស្សដ៏ទៃទៀត ដែលនោះអ្នកទាំងពីរជាគ្រីស្ទបរិសទ័ ។ ដោយហេតុផលនេះហើយ វាជាការគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមាននូវមិត្តភាពធម្មតា១ ។

## ៣. មិត្តភាពជិតស្និទ្ធ

### ក. ការពិពណ៌នា

មិត្តភាពនេះផ្អែកលើគោលដៅនៃជីវិតដែលស្រដៀងគ្នា ។ អ្នកប្រហែលជានឹងមានមិត្តភ័ក្តិជិតស្និទ្ធតិចតួច

ប្រហែលជា ៥, ១០ ឬក៏ ១៥នាក់ ប៉ុណ្ណោះ ។

### ខ. សិទ្ធិសេរីភាពរបស់អ្នក

អ្នកមានសេរីភាពក្នុងការផ្តល់យោបល់ឱ្យមានជាកម្មវិធី ដែលនឹងជួយអ្នកទាំងពីរបាន ។ ការនេះគឺជាអ្វីមួយដែលអ្នកទាំងពីរបានយល់ព្រមគ្នា ។ កុំអោយមានអារម្មណ៏មិនស្រួលក្នុងការផ្តល់មិត្តយោបល់ ។ សូមមើល កាឡាទី ៦:២

ជំរៅនៃមិត្តភាពរបស់អ្នកគឺជាប់ទាក់ទងដោយផ្ទាល់ទៅនឹងឆន្ទ:របស់មនុស្សម្នាក់ទៀត ដែលមានបំណងចង់បង្កើតមិតភាពនេះ ឬក៏ អត់ ។ អ្នកមិនអាចនិយាយថា "គាត់គឺជាមិត្តភ័ក្តិជិតស្និទ្ធរបស់ខ្ញុំ" ខណ:ដែលមនុស្សម្នាក់ទៀតនិយាយថា "អ្នកគ្រាន់តែជាមិត្តភ័ក្តិដែលគ្រាន់តែស្គាល់ប៉ុណ្ណោះ" ប្រសិនបើអ្នកចង់បានមិត្តភាពដ៏រឹងមាំ អ្នកទាំងពីរត្រូវមើលឃើញវាក្នុងវិធីដែលស្របគ្នា ។

### គ. ការទទួលខុសត្រូវរបស់អ្នក

(១) លើកទឹកចិត្តគាត់ ។ សុភាសិត ១២:២៥

(២) សរសេរលើចំនុចណាខ្លះ ដែលអាចជួយឱ្យអ្នកទាំងពីរស្របគ្នាបាន

មិត្តភាពជិតស្និទ្ធមិនមែនចាប់ផ្តើមថ្ងៃនេះ ហើយ បញ្ចប់ទៅវិញថ្ងៃស្អែកឡើយ ។ មិត្តភាពបែបនេះត្រូវការភាពស៊ីជំរៅរវាងអ្នកទាំងពីរ ។ មិត្តភាពរបស់អ្នកអាចឈររឹងមាំទៅបានតាមរយ:ការឆ្លងកាត់នូវពេលវេលាល្អ និង ពេលវេលាដ៏លំបាក។ជាមួយគ្នា ។

## ៤. មិត្តភាពស្និទ្ធស្នាល

### ក. ការពិពណ៌នា

មិត្តភាពបែបនេះគឺពឹងផ្អែកទៅលើការផ្តាច់ញ្ជោរចិត្តរបស់អ្នកទាំងពីរក្នុងការអភិវឌ្ឍន៏អត្តចិរតរបស់គ្នាទៅវិញទៅមក ។ មានមនុស្សជាច្រើនដែលគ្មានមិត្តស្និទ្ធស្នាលទេ ។ មិត្តភាពប្រភេទនេះគឺពិសេសណាស់--គឺពិតជាពិសេសណាស់ ។ អ្នកប្រហែលជាមានមិត្តភ័ក្តិប្រភេទនេះ ១ ឬ ២ ប៉ុណ្ណោះក្នុងជីវិតរបស់អ្នក ។

### ខ. សេរីភាពរបស់អ្នក

អ្នកមានសេរីភាពដើម្បីកែតំរង់ (មិនមែនរិះគន់ទេ) ដល់គ្នាទៅវិញទៅមកបាន ។ សេរីភាពបែបនេះអាចងាយស្រួលនឹងត្រូវបានខូចបង់ ។ សូមថែរក្សាសេរីភាពនេះដោយយកចិត្តទុកដាក់ឱ្យមែនទែន ។ ការកែតំរង់របស់អ្នកត្រូវផ្តើតលើចំនុចណាដែលធ្វើឱ្យជីវិតមិត្តនោះត្រូវបំផ្លាញ ។ ចំនុចអវិជ្ជមានគឺជាបញ្ហាមួយ ដែលអ្នកមិនពុំសូវចាប់អារម្មណ៏ថា ខ្លួនឯងមានទេ។

### គ. ការទទួលខុសត្រូវរបស់អ្នក

(១) អ្នកត្រូវតែមានភាពស្មោះត្រង់ដោយចំហរ ។ ប៉ុន្តែសូមប្រើដោយយកចិត្តទុកដាក់ ។ អ្នកត្រូវតែនិយាយសេចក្តីពិតនៅក្នុងសេចក្តីស្រលាញ់ ។ (អេភេសូ ៤:១៥)

(២) សូមផ្តល់ការទូន្មានជាវិជ្ជមាន ។ សូមកុំតិទៀនឡើយ ។ សូមមើល សុភាសិត ១២:២៦

**គ. ចុះចំណែកឯមិត្តភក្តិចាស់ដែលរស់នៅតាមចិញ្ចើមថ្នល់វិញ នោះយ៉ាងម៉េចដែរ?**

១. សំរេចចិត្តថាអ្នកដែលបដិសេធន៍ព្រះយេស៊ូត្រូវតែបដិសេធន៍អ្នកផងដែរ

២. សំរេចចិត្តប្រាប់ពួកគេថាអ្នកស្រលាញ់ព្រះយេស៊ូនៅពេលគេសូមអោយអ្នកធ្វើអំពើបាប

៣. សំរេចចិត្តអោយព្រះជាម្ចាស់ជ្រើសរើសមិត្តភ័ក្តិរបស់អ្នក

ក. ស្វែងរកអ្នកដែលត្រូវការមិត្តភ័ក្តិ

ខ. ស្វែងរកអ្នកដែលត្រូវការជំនួយ

**ឃ. ការឆ្លើយតបចំពោះសត្រូវរបស់អ្នក**

| ប្រតិកម្មរបស់គាត់ | ការឆ្លើយតបដោយប្រាជ្ញា (ធ្វើកិច្ចការនេះតាមវិធីរបស់ព្រះជាម្ចាស់) | ការឆ្លើយតបតាមបែបធម្មជាតិ (ធ្វើកិច្ចការនេះតាមវិធីរបស់ខ្ញុំ) |
|---|---|---|
| ១. គាត់មានប្រតិកម្មចំពោះខ្ញុំ | ពិនិត្យខ្លួនខ្ញុំផ្ទាល់ (ស្វែងរកចំនុចខ្សោយ) | ខ្ញុំខំការពារខ្លួនឯង សុភាសិត ១៨:១៧ |
| ២. គាត់រៀបចំផែនការសងសឹក | រកអោយឃើញតំរូវការ របស់គាត់ និង រងចាំ | បង្ខូចកិត្តិយសគាត់ រ៉ូម ១២:១៩ |
| ៣. គាត់រីកចំរើន | អំណរនៅក្នុងសេចក្តីល្អ របស់ព្រះជាម្ចាស់ | ច្រណែននឹងភាពចំរុងចំរើន របស់គាត់ ទំនុកតម្កើង ៧៣ |
| ៤. គាត់មានបញ្ហា | ជួយដោះស្រាយតំរូវ ការរបស់គាត់ សុភាសិត ២៤:១៧ | សប្បាយនៅក្នុងការធ្លាក់ចុះ និង បរាជ័យរបស់គាត់ |
| ៥. គាត់ត្រូវបានជាប់ទោស | ស្វែងរកការផ្តល់ប្រឹក្សា និង អធិស្ឋាន | គ្របបញ្ហារបស់យើង ម៉ាថាយ ៧:២ |

# ជំពូក ទី ២
## ផ្លូវភេទ និង ជីវិតគ្រីស្ទបរិស័ទ

តើផ្លូវភេទស៊ីគ្នានៅក្នុងជីវិតគ្រីស្ទបរិស័ទយ៉ាងដូចម្តេច? នៅក្នុងមុខវិជ្ជាដែលនៅសល់ផ្សេងទៀតនឹងព្យាយាមពន្យល់ចំលើយចំពោះសំនួរនេះ ។ ទាំងនេះគឺជាសំនួរខ្លះដែលអ្នកអាចគិតអំពី កំឡុងពេលពីរបីថ្ងៃបន្ទាប់ទៅមុខទៀត ។

តើអ្វីដែលធ្វើអោយការណាប់ជួបគ្នារវាងស្រីប្រុសមានភាពជោគជ័យដ៏មួយ?

តើអ្នកអាចមានការណាត់ជួបរវាងស្រីប្រុសដ៏មានជោគជ័យរាល់ពេលដែលអ្នកបន្តការណាត់ជួបដោយរបៀបណា?

តើព្រះជាម្ចាស់មានព្រះបន្ទូលយ៉ាងដូចម្តេចអំពីការមានការណាត់ជួបរវាងស្រីប្រុសដ៏ល្អបាន?

ចុះចំណែកការណាត់ជួបរវាងស្រីប្រុសដែលមិនមែនជាគ្រីស្ទបរិស័ទមានលក្ខណៈយ៉ាងដូចម្តេចដែរ?

តើគ្រីស្ទបរិស័ទអាចធ្វើអ្វីនៅពេលមានការណាត់ជួបរវាងស្រីប្រុសបានយ៉ាងណាខ្លះដែរ?

តើជីវិតផ្លូវភេទរបស់អ្នក មុនពេលអ្នករៀបការ វាជះឥទ្ធិពលយ៉ាងណាដែរ ក្រោយពីអ្នករៀបការហើយ?

តើអ្នកគួរតែធ្វើអ្វីខ្លះ ប្រសិនបើអ្នកស្រលាញ់នរណាម្នាក់ដែលមិនមែនជាគ្រីស្ទបរិស័ទ?

តើអ្វីទៅ ដែលធ្វើអោយអាពាហ៍ពិពាហ៍គ្រីស្ទបរិស័ទមានលក្ខណៈពិសេស?

តើអ្នកស្វែងរកដៃគូជីវិតដោយរបៀបណា?

តើអ្នកអាចស្តារអាពាហ៍ពិពាហ៍របស់អ្នកឡើងវិញបានដោយរបៀបណា?

តើចំណែកឯច្បាប់អាពាហ៍ពិពាហ៍ធម្មតា មានលក្ខណៈយ៉ាងដូចម្តេចដែរ?

សូមចាប់ផ្តើមមើល និង សិក្សាអោយកាន់តែស៊ីជំរៅបន្តិចស្តីអំពីការណាត់ជួបរវាងស្រីប្រុស ។

### ក. ការណាត់ជួបរវាងស្រីប្រុស

#### ១. តើគោលបំណងនៃការណាត់ជួបរវាងស្រីប្រុសគឺជាអ្វី?

**( តើហេតុអ្វីបានជាមនុស្សណាប់ជួបគ្នា? )**

គំរោងកិច្ចការ ទី ២នៅក្នុងសៀវភៅណែនាំការសិក្សាបានផ្តល់អោយអ្នកនូវឱកាសដើម្បីឆ្លើយសំនួរនេះ ។ អ្នកអាចមើលម្តងទៀតនូវចំលើយដែលអ្នកបានដាក់សំរាប់សំនួរលេខ ១ ។

នេះគឺជាចំលើយខ្លះៗដែលអ្នកដទៃបានផ្តល់អោយសំរាប់សំនួរនេះ ។

-- ស្គាល់មិត្តភ័ក្តិរបស់ខ្ញុំអោយកាន់តែប្រសើរឡើង

-- រីកចំរើននៅក្នុងភាពជាចាស់ទុំក្នុងសង្គម

-- រៀនពីរបៀបស្រី (ឬក៏ ប្រុស)គិត

-- ចែកចាយអារម្មណ៍របស់ខ្ញុំជាមួយពួកគេ

-- រៀបចំសំរាប់អាពាហ៍ពិពាហ៍

-- រៀនពីរបៀបមានអារម្មណ៍ងាយស្រួល( សុខស្រួល) នៅជុំវិញមនុស្សដែលមានភេទផ្ទុយគ្នា

ហេតុផលសំខាន់ពីរយ៉ាងដែលគ្រីស្ទបរិស័ទណាត់ជួបរវាងស្រីប្រុសត្រូវបានបង្ហាញខាងក្រោមនេះ ។

ក. រៀនពីរបៀបផ្តល់ និង ទទួលសេចក្តីស្រលាញ់ជាពិសេសសេចក្តីស្រលាញ់អាកាបេ គឺជាសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់

ខ. ផ្តល់ជាឱកាសសំរាប់យើងទាំងពីរនាក់ចូលខិតទៅជិតព្រះជាម្ចាស់

ប្រសិនបើកិច្ចការទាំងពីរនេះមិនកើតឡើងនៅក្នុងការណាត់ជួបរវាងស្រីប្រុសរបស់អ្នកនោះទេ នោះមានន័យថា អ្នកនឹងខកខាននូវអំណរដ៏សប្បាយរីករាយខ្លះ ដែលកើតចេញពីការណាត់ជួយរវាងស្រីប្រុស ។ ប៉ុន្តែកិច្ចការពីរចុងក្រោយនេះប្រហែលជាកិច្ចការដ៏ លំបាកបំផុត ដើម្បីទទួលអោយនូវភាពជោគជ័យដែលកើតចេញពីការណាត់ជួបរវាងស្រីប្រុសនេះ ។

**២. តើមនុស្សម្នាក់ត្រៀមខ្លួនរួចជាស្រេចដើម្បីចាប់ផ្តើមចេះណាត់ជួបរវាងស្រីប្រុសនៅពេលណា?**

ក. នៅពេលដែលអ្នកយល់ដឹងពីផលប្រយោជន៏ ( កិច្ចការល្អ) និង គ្រោះថ្នាក់នៃការណាត់ជួប ។

ខ. នៅពេលដែលអ្នកធ្វើតាមនូវគំរូបទដ្ឋានដោយលក្ខណៈផ្ទាល់ខ្លួន ។ ( ច្បាប់សំរាប់ការណាត់ជួប)

គ. នៅពេលដែលអ្នកបានយល់ព្រមជាមួយនឹងព្រះជាម្ចាស់ថាមិនត្រូវបន្ទាប់បទដ្ឋានរបស់អ្នកនោះទេ ។ នៅពេលដែលអ្នកសំរបសំរួល ការល្បួងរបស់អារក្សសាតាំងនឹងកាន់តែខ្លាំងឡើង អ្នកកាន់តែខ្សោយចុះ ហើយមិនយូរមិនឆាប់អ្នកនឹងមានគំនិតនៃអំពើបាប ហើយទីបញ្ចប់អ្នកប្រព្រឹត្តអំពើបាបតែម្តង ។

**៣. តើអ្វីទៅដែលជាផលប្រយោជន៏កើតចេញពីការណាត់ជួបរវាងស្រីប្រុស?**

សូមពិនិត្យមើលចំលើយរបស់អ្នកសំរាប់សំនួរទី ៣ នៅក្នុងគំរោងកិច្ចការទី២ នៅក្នុងសៀវភៅណែនាំសិក្សារបស់អ្នក ។ ហើយសូមពិនិត្យមើលផងដែរនូវកំណត់សំគាល់របស់អ្នកពីថ្នាក់រៀនសំរាប់ជាគំនិតនៅក្នុងចំនុចនេះ ។

**៤. តើសញ្ញាគ្រោះថ្នាក់ ដែលកើតចេញពីការណាត់ជួបរវាងស្រីប្រុសមានជាអ្វីខ្លះ?**

សូមពិនិត្យមើលចំលើយរបស់អ្នកសំរាប់សំនួរទី ៤ នៅក្នុងគំរោងកិច្ចការ ទី២ នៅក្នុងសៀវភៅណែនាំសិក្សារបស់អ្នក ។ ហើយសូមពិនិត្យមើលផងដែរនូវកំណត់សំគាល់របស់អ្នកពីថ្នាក់រៀនសំរាប់ជាគំនិតនៅក្នុងចំនុចនេះ ។

**ខ. អាពាហ៍ពិពាហ៍**

**១. តើអ្នកអាចរៀបចំខ្លួនសំរាប់អាពាហ៍ពិពាហ៍ដ៏ជោគជ័យមួយបានយ៉ាងដូម្តេចខ្លះ?**

ក. អ្នកត្រូវតែរីកចំរើនខាងទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ

ខ. អ្នកត្រូវតែរៀនទទួលយកខ្លួនឯង

គ. អ្នកត្រូវតែរៀនស្តាប់បង្គាប់ចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់

ឃ. អ្នកត្រូវតែមានមនសិការច្បាស់លាស់

ង. អ្នកត្រូវតែចេះបញ្ចេញកំហឹងរបស់អ្នកតាមគំរូព្រះគម្ពីរ ។ អ្នកត្រូវតែចេះថ្វាយសិទ្ធផ្ទាល់ខ្លួនដល់

ព្រះជាម្ចាស់ ។

ច. អ្នកត្រូវចេះបង្កើតលក្ខណៈសម្បត្តិជាវិជ្ជមានខាងក្នុងនៃការចេះទប់ចិត្តខ្លួន ជាពិសេសនៅក្នុងបញ្ហាអាកប្បកិរិយាខាងផ្លូវភេទរបស់អ្នក ។

ឆ. អ្នកត្រូវតែសំរេចចិត្តថា អ្វីទៅជាគោលដៅនៃជីវិតរបស់អ្នក ។ ទិសដៅមួយនៅក្នុងចំណោមទិសដៅទាំងនេះគឺត្រូវដឹងថា ការងារប្រភេទណាដែលអ្នកនឹងត្រូវធ្វើ ។

ជ. ឱយុវជនអើយ--អ្នកត្រូវតែអាចឧបត្ថម្ភគ្រួសាររបស់អ្នកខាងផ្នែកហិរញ្ញវត្ថុបាន ។ អ្នកមិនត្រូវជំពាក់បំណុលរបស់អ្នកណាម្នាក់នោះទេ ។

## ២. គំរូរបស់ព្រះជាម្ចាស់សំរាប់អាពាហ៍ពិពាហ៍ដ៏ជោគជ័យ

**ម៉ាថាយ ១៩:៥**

" រួចព្រះអង្គមានព្រះបន្ទូលថា : ហេតុនេះហើយបានជាបុរសត្រូវចាកចេញពីឪពុកម្តាយ ទៅរួមរស់ជាមួយនឹងភរិយារបស់ខ្លួន ហើយអ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ ។ "

**ម៉ាថាយ ១៩:៥** "ដូចមានចែងមកថា ដោយហេតុនេះហើយបុរសនឹងចាកចេញពីឪពុកម្តាយរបស់គាត់ ហើយទៅរួមរស់ជាមួយនឹងភរិយារបស់គាត់ អ្នកទាំងពីរនឹងក្លាយជារូបកាយតែមួយ ។

ព្រះជាម្ចាស់បានផ្តល់អោយយើងនូវការណែនាំ បីយ៉ាងដើម្បីអោយមានអាពាហ៍ពិពាហ៍មួយដ៏ជោគជ័យ ។

### ក. ការចាកចេញ

(១) ខាងសរីរាង្គកាយ - អាពាហ៍ពិពាហ៍ស្របច្បាប់
- មានផ្ទះនៅខ្លួនឯង ឬ ជួល

(២) ខាងអារម្មណ៏ - រៀបការដោយមានការយល់ពីឪពុកម្តាយ
- រៀបការដោយមានការយល់ព្រមពីព្រះជាម្ចាស់

### ខ. ការស្អិតជាប់ជាមួយគ្នា

(១) ខាងសរីរាង្គកាយ - រស់នៅជាមួយគ្នា

(២) ខាងចិត្តសាស្រ្ត - សេចក្តីស្រលាញ់ ( កូឡូស ៣:១៤)
- សេចក្តីស្មោះត្រង់
- ២ កូរិនថូស ៦:១៤
( កុំរៀបការជាមួយនឹងអ្នកមិនជឿ)

### គ. ក្លាយទៅជារូបកាយតែមួយ

(១) ខាងសរីរាង្គកាយ - ផ្លូវភេទ

(២) ខាងចិត្តសាស្រ្ត - មានអាកប្បកិរិយាដូចគ្នា

- ចែករំលែកជាមួយគ្នាគ្រប់អ្វីៗទាំងអស់

(៣) ខាងព្រលឹងវិញ្ញាណ - គោលដៅខាងព្រលឹងវិញ្ញាណដូចគ្នា ( ទាំងពីរបំរើព្រះជាម្ចាស់ )

- ២ កូរិនថូស ៦:១៤

## សំនួរបន្ថែមខ្លះៗទៀតជាជំនួយក្នុងការសិក្សា

១. តើអ្វីទៅជាគោលបំណងនៃអាពាហ៍ពិពាហ៍? ( តើហេតុអ្វីបានជាមនុស្សរៀបការ? )

២. តើមនុស្សម្នាក់អាចរៀបការបាននៅវ័យណា?

៣. តើអ្វីខ្លះទៅដែលជាផលប្រយោជន៍បានពីការរៀបការ?

៤. តើអ្វីខ្លះទៅជាសញ្ញាគ្រោះថ្នាក់នៃការរៀបការ?

៥. ឥឡូវនេះ គឺខ្ញុំជាគ្រីស្ទបរិស័ទ តើអាកប្បកិរិយារបស់ខ្ញុំគួរត្រូវផ្លាស់ប្តូរយ៉ាងណាដែរចំពោះការរួមភេទ?